# ភ្លេច សួរខ្លួនឯង

តើសំណួរអ្វីខ្លះដែលកប់ជ្រៅនៅក្នុងខ្លួនរបស់អ្នក?
តើអ្វីជាចម្លើយចំពោះសំណួរទាំងនោះ?



# ភ្លេច សួរខ្លួនឯង

តើសំណួរអ្វីខ្លះដែលកប់ជ្រៅនៅក្នុងខ្លួនរបស់អ្នក?

តើអ្វីជាចម្លើយចំពោះសំណួរទាំងនោះ?



## ជម្រាបសួរ មិត្តអ្នកអានជាទីគោរពរាប់អាន!

តើលោកអ្នកធ្លាប់មានសំណួរនៅក្នុងខ្លួន ឬធ្លាប់ដែលសួរខ្លួនឯងទេថា៖

- តើនរណាជាអ្នកបង្កើតខ្ញុំ ហើយបង្កើតមកក្នុងគោលបំណងអ្វី?
- តើខ្ញុំត្រូវទៅទីណាបន្ទាប់ពីស្លាប់ ហើយវាសនារបស់ខ្ញុំនឹងទៅជាយ៉ាងណា?
- តើកន្លែងចុងក្រោយរបស់ខ្ញុំជាអ្វី?
- តើហេតុផលនៃវត្ថុមានទាំងអស់នៅលើលោកនេះជាអ្វី?
- តើវាស័ក្តិសមដែរទេ ប្រសិនបើទីបញ្ចប់នៃជីវិតរបស់ខ្ញុំគ្រាន់តែជាការស្លាប់ ក្លាយទៅជាដី និងត្រូវរលាយសាបសូន្យនោះ?
- តើវាមិនមែនជារឿងដ៏គួរឱ្យភ័យខ្លាចទេឬ ប្រសិនបើរូបខ្ញុំមិនទាន់បានត្រៀមខ្លួនសម្រាប់ជីវិតក្រោយពេលស្លាប់?



នៅពេលដែលមនុស្សម្នាក់សញ្ជឹងគិតអំពីផែនដីដែលពួកគេរស់នៅ មើលទៅកាន់សកលលោកដ៏ធំល្វឹងល្វើយ មេឃដែលលម្អដោយដួងតារាជាច្រើន ហើយនិងផែនដីដែលមានភ្នំ ទន្លេ បឹងបួ ដើមឈើ ដំណាំដាំដុះ ខ្យល់ ទឹក ដីគោក សមុទ្រ ពេលយប់ និងពេលថ្ងៃ ទាំងអស់នេះដំណើរការទៅតាមប្រព័ន្ធប្រក្រតីភាព និងគន្លងរបស់វាដោយល្អតតខ្ចោះបែបនេះ នោះគេចាំបាច់ត្រូវតែសួរខ្លួនឯងថា៖

- តើនរណាជាអ្នកបង្កើតអ្វីៗទាំងអស់នេះ?
- តើនរណាជាអ្នកបញ្ជូនទឹកភ្លៀងពីលើមេឃ ហើយធ្វើឱ្យមានរុក្ខជាតិ បន្លែ ផ្លែឈើគ្រប់ប្រភេទដុះចេញមក?
- តើនរណាជាអ្នកបង្កើតឱ្យមានទឹកដែលជីវិតមិនអាចរស់ដោយគ្មានវាបាន?
- តើនរណាជាអ្នកបង្កើតផែនដីដែលអាចរក្សាអ្វីទាំងអស់នេះបាន?
- តើនរណាជាអ្នកបង្កើតមនុស្សលោកឱ្យមានរូបរាងដ៏ល្អតតខ្ចោះបែបនេះ?



នៅពេលដែលមនុស្សម្នាក់សញ្ជឹងគិតអំពីខ្លួនឯង នោះគេនឹងរកឃើញភាពអស្ចារ្យនៃអ្នកដែលបង្កើត និងភាពល្អឯកនៃកិច្ចការរបស់គេ។ ចូរពិចារណាទៅលើប្រព័ន្ធសរីរាង្គផ្សេងៗនៃរាងកាយរបស់អ្នកដ៏សែនស្មុគស្មាញដែលដំណើរការយ៉ាងហ្មត់ចត់ និងបំពេញតួនាទីរបស់វាយ៉ាងល្អ។

អ្នកអាចនឹងបានដឹងតិចតួចបំផុតអំពីដំណើរការរបស់វា ហើយអ្នកក៏គ្មានសមត្ថភាពនៅក្នុងការគ្រប់គ្រងវានោះឡើយ។ ចូរសង្កេតមើលទៅខ្យល់ដែលអ្នកដកដង្ហើម។ ប្រសិនបើវាឈប់មួយរំពេច នោះអ្នកនឹងបាត់បង់ជីវិតជាមិនខាន។

តើមនុស្សដែលមានបញ្ញាញាណគិតថា សកលលោក និងអ្វីៗទាំងអស់ត្រូវបានបង្កើតឡើងដោយឥតប្រយោជន៍ ហើយមនុស្សកើតមករស់នៅលើផែនដីនេះត្រឹមមួយរយៈពេល បន្ទាប់មកក៏ស្លាប់ ហើយអ្វីៗក៏ចប់ឬ?

តើសកលលោកកើតឡើងដោយចៃដន្យ ឬក៏កើតឡើងដោយឯកឯងឬ?

មិនអាចទៅរួចនោះឡើយ គឺត្រូវតែមាននរណាម្នាក់ដែលមានប្រាជ្ញាញាណពេញលេញបង្កើតអ្វីទាំងអស់នេះ។



ពិតប្រាកដណាស់ ព្រះជាម្ចាស់គឺជាអ្នកដែលបង្កើតអ្វីៗទាំងអស់។ ទ្រង់បានបង្កើតអ្នក និងសកលលោកទាំងមូលនេះពីភាពទទេគ្មានអ្វីសោះ។ ទ្រង់តែមួយព្រះអង្គគត់ដែលជាអ្នកគ្រប់គ្រង និងដឹកនាំគ្រប់យ៉ាង។ ហើយទ្រង់ក៏ជាអ្នកដែលផ្តល់នូវលាភសក្ការៈ ផ្តល់នូវជីវិតរស់នៅ និងសេចក្តីស្លាប់ផងដែរ។

តើអ្នកគិតថា អ្នកមិនគួរនឹងចំណាយពេលដើម្បីស្គាល់ព្រះដែលបង្កើតអ្នក និងស្គាល់ពីអ្វីដែលទ្រង់ចង់បានពីអ្នកទេឬ?

ហេតុអ្វីបានជាទ្រង់បង្កើតយើងមក? ហើយតើនរណាជាអ្នកដែលអាចឆ្លើយនូវរាល់សំណួរទាំងអស់របស់អ្នកបាន?

ព្រះជាម្ចាស់បានជំរុញឲ្យយើងសញ្ជឹងគិត ប្រើហេតុផល និងធ្វើការវិនិច្ឆ័យដោយផ្អែកលើភស្តុតាងត្រឹមត្រូវ។ ទ្រង់បានមានបន្ទូលប្រាប់យើងអំពីអ្នកដែលប្រើហេតុផល និងការគិតពិចារណាថា៖



តើអ្នកមិនចាប់អារម្មណ៍សិក្សាឲ្យស៊ីជម្រៅអំពីសាសនាដែលរីកសុសសាយយ៉ាងលឿនបំផុតដូចដែលស្ថិតិពិភពលោកបានបង្ហាញទេឬ?

តើហេតុផលដែលនៅពីក្រោយរឿងនោះគឺជាអ្វី?

តើអ្នកគិតយ៉ាងណាដែរ ប្រសិនបើអ្នកផ្តល់ឱកាសឲ្យខ្លួនឯងយ៉ាងហោចណាស់ឱ្យបានម្តងក្នុងជីវិតរបស់អ្នក ដើម្បីស្គាល់សាសនាអ៊ីស្លាមពីប្រភពដែលត្រឹមត្រូវបន្ទាប់មក ធ្វើការវិនិច្ឆ័យដោយផ្អែកលើមូលដ្ឋាន និងសុឆន្ទៈពិតប្រាកដនោះ?

**អ៊ីស្លាម** គឺជាការចុះចូលចំពោះព្រះជាម្ចាស់(អល់ឡោះ)ដែលជាអ្នកបង្កើត និងគ្រប់គ្រងសកលលោក ហើយត្រូវគោរពតាមបញ្ជារបស់ទ្រង់ដោយសេចក្តីគោរពស្រឡាញ់។ ដោយមូលដ្ឋានគ្រឹះនៃជំនឿនៅក្នុងសាសនាអ៊ីស្លាម គឺការមានជំនឿលើអល់ឡោះថា ទ្រង់ជាអ្នកដែលបង្កើត ហើយអ្វីៗផ្សេងក្រៅពីទ្រង់ គឺជាការបង្កើតរបស់ទ្រង់។ ទ្រង់ជាអ្នកដែលស័ក្តិសមនឹងគោរពសក្ការៈតែមួយព្រះអង្គគត់។ គ្មានព្រះឯណាដែលត្រូវគោរពសក្ការៈដ៏ត្រឹមត្រូវក្រៅពីទ្រង់ឡើយ។

អ៊ីស្លាមជាសាសនាដែលស៊ីចង្វាក់នឹងហេតុផល និងស្របតាមធម្មជាតិ ដោយដួងចិត្តដ៏បរិសុទ្ធនឹងទទួលយក។

ជាសាសនានៃព្រះជាអម្ចាស់ដែលជាអ្នកបង្កើត ដោយព្រះអង្គបានដាក់វាជាបញ្ញត្តិសម្រាប់ភាវៈដែលទ្រង់បានបង្កើត។ ដូច្នេះទ្រង់មិនទទួលយកសាសនាផ្សេងឡើយ។

ជាសាសនាដែលព្យាការី និងអ្នកនាំសារទាំងឡាយបាននាំមក។

ជាសាសនានៃសេចក្តីល្អ និងសុភមង្គលសម្រាប់មនុស្សគ្រប់គ្នា ដោយមិនរើសអើងពូជសាសន៍ ឬពណ៌សម្បុរឡើយ។



មនុស្សគ្រប់រូបមានភាពស្មើគ្នានៅក្នុងសាសនាអ៊ីស្លាម។ គ្មាននរណាម្នាក់ត្រូវបានសម្គាល់លើសពីអ្នកដទៃឡើយ លើកលែងតែតាមរយៈការប្រព្រឹត្តសុចរិតរបស់ពួកគេដែលផ្តល់ផលប្រយោជន៍ដល់ខ្លួនឯង និងអ្នកដទៃប៉ុណ្ណោះ។

អ្នកដែលចង់ចូលសាសនាអ៊ីស្លាម គឺគេគ្រាន់តែពោលពាក្យខាងក្រោមនេះ ប្រកបដោយជំនឿពិតប្រាកដ និងយល់ដឹងពីអត្ថន័យរបស់វាថា៖

*«ទូលបង្គំសូមសច្ចាថា គ្មានទេព្រះដែលស័ក្តិសមនឹងគោរពសក្ការៈ លើកលែងតែអល់ឡោះ ហើយមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់ទ្រង់»*

បន្ទាប់មក ត្រូវរៀនអំពីបទបញ្ញត្តិផ្សេងៗទៀតនៃសាសនាអ៊ីស្លាមបន្តិចម្តងៗ ដើម្បីបំពេញកាតព្វកិច្ចដែលអល់ឡោះបានកំណត់។

## ព្រះនាម “អល់ឡោះ” នៅក្នុងភាសាអារ៉ាប់ មានអត្ថន័យដូចខាងក្រោម៖

**ទី១ ៖** មានន័យថា៖ ជាម្ចាស់ដែលត្រូវបានគេគោរពសក្ការៈ ដោយការគោរពសក្ការៈទាំងអស់ត្រូវធ្វើទៅកាន់ទ្រង់តែមួយព្រះអង្គគត់។ ទ្រង់ជាអង្គដ៏ឧត្តុង្គឧត្តមនិងមានលក្ខណៈសម្បត្តិដ៏អស្ចារ្យដែលគំនិតនៃភាវៈទាំងពួងមិនអាចស្រមៃដល់នោះឡើយ។ ប៉ុន្តែដួងចិត្តពិតជាជាប់ជំពាក់នឹងទ្រង់ ហើយដួងវិញ្ញាណពិតមានសេចក្តីត្រូវការចំពោះទ្រង់ ស្វែងរកភាពធូរស្រាលនៅក្នុងការរឭកទៅកាន់ទ្រង់ រីករាយនឹងការបង្កើនភាពជិតស្និទ្ធ និងការគោរពសក្ការៈទៅចំពោះទ្រង់។

**ទី២ ៖** មានន័យថា៖ ជាម្ចាស់បង្កើតសកលលោក និងប្រព័ន្ធដំណើរការរបស់វា ហើយនិងអ្វីទាំងអស់ដែលមាននៅក្នុងវា។ ទោះបីជាតូចយ៉ាងណាក៏ដោយ គឺសុទ្ធតែជាការបង្កើតរបស់ទ្រង់ វាកើតឡើងតាមបំណង ការកំណត់ និងប្រាជ្ញាញាណរបស់ទ្រង់។ រាល់តំណក់ទឹកភ្លៀងដែលធ្លាក់ចុះ ឬការផ្លាស់ប្តូរពេលវេលាពេលថ្ងៃ និងយប់ អ្វីដែលលាតត្រដាង ឬលាក់កំបាំង និងអ្វីដែលស្ថិតនៅផ្នែកណាមួយនៅក្នុងសកលលោកនេះ គឺសុទ្ធតែត្រូវបានអល់ឡោះជ្រាបដឹងអំពីវា។

**ទី៣ ៖** មានន័យថា៖ ជាម្ចាស់គ្រប់គ្រងដ៏យុត្តិធម៌បំផុត ទ្រង់មិនបំពានសូម្បីតែទម្ងន់ប៉ុនអាតូមដ៏តូចនោះឡើយ។ អ្វីដែលយើងបានឃើញនៅក្នុងជីវិតបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីព្រះប្រាជ្ញាញាណ និងសេចក្ដីសប្បុរសនៃទ្រង់។

នៅពេលដែលមានអ្នកខ្លះអះអាងថា អល់ឡោះបានបង្កើតមេឃ និងផែនដីក្នុងរយៈពេលប្រាំមួយថ្ងៃ ហើយបន្ទាប់មក ទ្រង់សម្រាកនៅថ្ងៃទីប្រាំពីរនោះ ព្រះគម្ពីរគួរអានបានបដិសេធការអះអាងយ៉ាងដូច្នេះ ដោយទ្រង់មានបន្ទូលយ៉ាងច្បាស់ថា៖

« ហើយយើងពិតជាបានបង្កើតមេឃជាច្រើនជាន់និងផែនដី និងអ្វីៗដែលមាននៅចន្លោះវាទាំងពីរក្នុងរយៈពេលប្រាំមួយថ្ងៃ ហើយយើងគ្មានការនឿយហត់នោះឡើយ។ »
[ព្រះគម្ពីរគួរអាន ៥០ ៖ ៣៨]

ការអះអាងរបស់គេនេះ គ្រាន់តែជាគំនិត និងជាការវិនិច្ឆ័យនូវអ្វីដែលមានភាពប្រហាក់ប្រហែលនឹងខ្លួនឯង ឬជាភារៈដែលមនុស្សអាចគិតទៅដល់ប៉ុណ្ណោះ។ ប៉ុន្តែព្រះអង្គ គឺខុសពីការគិតទាំងនោះ ព្រោះទ្រង់ជាអ្នកដែលបង្កើត ទ្រង់មានលក្ខណៈខុសពីអ្វីដែលទ្រង់បានបង្កើត។ តើអ្វីដែលជាការបង្កើតរបស់ទ្រង់អាចប្រៀបធៀបជាមួយនឹងទ្រង់ដែលជាអ្នកបង្កើតដោយរបៀបណា?

យើងសង្កេតឃើញថា សូម្បីក្មេងតូចក៏មិនអាចយល់ពីសកម្មភាពមួយចំនួនរបស់ឪពុកម្ដាយរបស់ពួកគេ ហើយក៏មិនអាចនឹងពន្យល់ឱ្យពួកគេបានយល់ឡើយ ព្រោះតែភាពខុសគ្នាយ៉ាងខ្លាំងអំពីសមត្ថភាពនៃការគិតរបស់ពួកគេ។ យ៉ាងណាមិញ គំនិតរបស់មនុស្សនៅក្នុងការយល់ពីការបង្កើតរបស់ព្រះជាម្ចាស់ និងព្រះបញ្ញាញាណរបស់ទ្រង់ គឺវាពិតជាមានកង្វះខាតច្បាស់ណាស់។

« តាមពិត បញ្ជារបស់ទ្រង់ នៅពេលដែលទ្រង់មានព្រះបំណងប្រាថ្នាអ្វីមួយ គឺទ្រង់គ្រាន់តែមានបន្ទូលទៅកាន់វាថា៖ «ចូរកើតចុះ» នោះវានឹងកើតភ្លាម។ »
[ព្រះគម្ពីរគួរអាន ៥០ ៖ ៣៨]

## មនុស្សដំបូងនៅលើផែនដី

មនុស្សដំបូងបង្អស់ដែលព្រះជាម្ចាស់បានបង្កើត គឺអាដាំ។ លោកគឺជាបិតានៃមនុស្សជាតិ និងជាអ្នកនាំសារដំបូងគេផងដែរ។ ទ្រង់បានបង្កើតលោកអំពីដីឥដ្ឋ (ផ្សំពីទឹកនិងដី) បន្ទាប់មក ទ្រង់បានធ្វើឱ្យលោកមានជារូបរាងឡើង ហើយក៏បានផ្លុំវិញ្ញាណចូលទៅក្នុងខ្លួនលោក។ ក្រោយមកទៀត ទ្រង់បានបង្កើតភរិយារបស់លោកចេញពីខ្លួនលោក ដោយបានដកយកឆ្អឹងជំនីខាងឆ្វេងរបស់លោកមួយ។ បន្ទាប់មក ទ្រង់បានបង្កើតកូនចៅរបស់លោកពីសារធាតុរាវ(ទឹកកាម)នៅក្នុងទីកន្លែងដែលមានសុវត្ថិភាព(នៅក្នុងស្បូន)។

« ហើយជាការពិតណាស់ យើងបានបង្កើតមនុស្សលោក(អាដាំ) ពីដីឥដ្ឋ(ផ្សំពីទឹកនិងដី)។ ក្រោយមក យើងបានបង្កើតគេពីទឹកកាម នៅក្នុងកន្លែងដែលមានសុវត្ថិភាព(នៅក្នុងស្បូន)។ »

[ព្រះគម្ពីរគួរអាន ២៣ ៖ ១២-១៣]



## ហេតុអ្វីបានជាព្រះជាម្ចាស់បង្កើតយើងមក?

ចម្លើយចំពោះសំណួរដ៏ធំនេះមានសារសំខាន់ខ្លាំងណាស់ ហើយវាចាំបាច់នៅក្នុងការផ្តល់ចម្លើយពីការបើកបង្ហាញអំពីបន្ទូលនៃព្រះជាម្ចាស់។ អល់ឡោះគឺជាម្ចាស់ដែលបានបង្កើតយើង។ ដូច្នេះ ទ្រង់ក៏ជាម្ចាស់ដែលប្រាប់យើងអំពីគោលបំណងដែលទ្រង់បានបង្កើតយើងមកដូចគ្នា។

« ហើយយើងមិនបានបង្កើតអមនុស្ស(ជិន) និងមនុស្សមកឡើយ លើកលែងតែដើម្បីឱ្យពួកគេគោរពសក្ការៈមកចំពោះយើងប៉ុណ្ណោះ។ »

[ព្រះគម្ពីរគួរអាន ៥១ ៖ ៥៦]

រាល់ភារៈទាំងអស់របស់អល់ឡោះត្រូវបានបង្កើតឡើង និងបានដាក់នូវទំនោរធម្មជាតិនៃជំនឿនៅក្នុងខ្លួនរបស់ពួកគេចំពោះការគោរពសក្ការៈ និងការលើកតម្កើងព្រះជាម្ចាស់នៃឋានទាំងអស់៖

« មេឃទាំងប្រាំពីរជាន់និងផែនដី និងអ្វីៗដែលមាននៅក្នុងនោះសុទ្ធតែសរសើរតម្កើងទ្រង់។ ហើយគ្មានអ្វីមួយដែលមិនសរសើរតម្កើងទ្រង់ឡើយ ប៉ុន្តែពួកអ្នកមិនបានយល់ពីការសរសើរតម្កើងរបស់ពួកគេនោះឡើយ។ »
[ព្រះគម្ពីរគួរអាន ១៧ ៖ ៤៤]

ប៉ុន្តែការគោរពសក្ការៈ និងការសរសើរតម្កើងរបស់មនុស្សចំពោះព្រះជាម្ចាស់ គឺជាជម្រើសរបស់ពួកគេ មិនមែនជាការបង្ខំនោះឡើយ។

« ទ្រង់គឺជាអ្នកម្ចាស់ដែលបានបង្កើតពួកអ្នក។ ដូច្នេះ នៅក្នុងចំណោមពួកអ្នកគឺមានអ្នកដែលគ្មានជំនឿ និងមានអ្នកដែលមានជំនឿ ហើយអល់ឡោះទតឃើញនូវអ្វីដែលពួកអ្នកប្រព្រឹត្ត។ » [ព្រះគម្ពីរគួរអាន ៦៤ ៖ ២]

« តើអ្នកមិនបានឃើញទេឬថា ពិតណាស់ អល់ឡោះគឺត្រូវបានអ្នកនៅលើមេឃជាច្រើនជាន់ និងអ្នកដែលនៅលើផែនដី ព្រះអាទិត្យ ព្រះចន្ទ ដួងតារា ភ្នំ ដើមឈើ សត្វ និងមនុស្សជាច្រើន(ដែលជាអ្នកមានជំនឿ) ក្រាបថ្វាយបង្គំទ្រង់នោះ? ហើយមនុស្សភាគច្រើន(ដែលជាអ្នកគ្មានជំនឿ) គឺត្រូវទទួលទណ្ឌកម្ម។ ហើយជនណាដែលអល់ឡោះធ្វើឲ្យគេអាម៉ាស់ គឺគ្មាននរណាម្នាក់អាចផ្តល់កិត្តិយសដល់គេបានឡើយ។»
[ព្រះគម្ពីរគួរអាន ២២ ៖ ១៨]

អល់ឡោះជាម្ចាស់ទ្រង់បានបង្កើតយើងមក គឺដើម្បីគោរពសក្ការៈចំពោះទ្រង់ និងដើម្បីសាកល្បងចំពោះការខិតខំប្រឹងប្រែងរបស់យើងនៅក្នុងការសម្រេចនូវការគោរពសក្ការៈនេះ។ អ្នកដែលគោរពសក្ការៈអល់ឡោះជាម្ចាស់ ស្រឡាញ់ទៅចំពោះទ្រង់ ចុះចូលចំពោះទ្រង់ គោរពតាមបញ្ញត្តិរបស់ទ្រង់ ហើយនិងចៀសសវាងនូវអ្វីដែលទ្រង់ហាមឃាត់ នោះនឹងទទួលបានការស្រឡាញ់ពេញចិត្ត និងរង្វាន់ដ៏គាប់ប្រសើរពីទ្រង់ នោះគឺឋានសួគ៌ដ៏ប្រសើរថ្លៃថ្លា។

ចំណែកអ្នកដែលបដិសេធមិនគោរពសក្ការៈអល់ឡោះដែលជាម្ចាស់បង្កើតពួកគេ ផ្តល់លាភសក្ការៈដល់ពួកគេ បដិសេធមិនគោរពតាមបញ្ញត្តិរបស់ទ្រង់ មិនចៀសវាងនូវអ្វីដែលទ្រង់ហាមឃាត់នោះ នឹងត្រូវទទួលរងនូវការក្រោធខឹង និងការដាក់ទណ្ឌកម្មដ៏ឈឺចាប់ពីទ្រង់ ។

ព្រះជាម្ចាស់មិនបានបង្កើតយើងដោយគ្មានគោលដៅឡើយ ហើយក៏មិនទុកឲ្យយើងវង្វេងដែរ។ មនុស្សដែលខ្វះការពិចារណា គឺអ្នកដែលទ្រង់បានផ្តល់ឱ្យនូវការស្តាប់ឮ ការមើលឃើញ និងប្រាជ្ញាញាណដើម្បីគិតពិចារណា ក៏ប៉ុន្តែពួកគេគិតថា វត្តមានរបស់ពួកគេនៅលើលោកិយនេះ គឺគ្រាន់តែដើម្បីរស់នៅត្រឹមមួយរយៈពេល ហើយក៏ត្រូវស្លាប់ទៅវិញ និងមិនដឹងថា ហេតុអ្វីបានជាពួកគេមកកាន់លោកិយនេះ ហើយនិងត្រូវទៅទីណាបន្ទាប់ពីនេះឡើយ។

« តើពួកអ្នកគិតថា យើងបានបង្កើតពួកអ្នកមក គឺគ្រាន់តែជាការលេងសើច ដោយគ្មានគោលបំណង ហើយពួកអ្នកនឹងមិនត្រឡប់មកជួបយើងវិញទេឬ? »
[ព្រះគម្ពីរគួរអាន ២៣ ៖ ១១៥]

## លក្ខណសម្បត្តិនៃអល់ឡោះជាម្ចាស់

អល់ឡោះជាម្ចាស់មានព្រះនាម និងលក្ខណសម្បត្តិដ៏សិរីរុងរឿង និងឧត្តុង្គឧត្តមបំផុត។ ហើយការស្គាល់ព្រះនាម និងលក្ខណសម្បត្តិរបស់ទ្រង់ នឹងជួយបង្កើនសេចក្តីស្រឡាញ់ ការគោរព ការកោតខ្លាច និងការចុះចូលចំពោះទ្រង់។ ទ្រង់តែមួយព្រះអង្គគត់ជាអ្នកដែលបង្កើត អ្នកផ្តល់ពរជ័យ ផ្តល់លាភសក្ការៈ ផ្តល់ជីវិតរស់នៅ និងសេចក្តីស្លាប់។ ដូច្នេះ ការថ្វាយបង្គំ ការចុះចូល ការអធិដ្ឋាន ការបួងសួងសុំជំនួយ មិនគួរត្រូវបានប្រណិប័តន៍ ឬស្វែងរកពីអ្នកណាផ្សេងក្រៅពីទ្រង់នោះឡើយ មិនថាជាអ្នកនាំសារ ជាទេវតា ឬជាបព្វជិតក៏ដោយ។

មានជំពូកមួយនៅក្នុងគម្ពីរគួរអាន ដែលជាជំពូកដ៏សំខាន់ និងអស្ចារ្យបំផុត ដោយបានបង្ហាញឱ្យយើងបានដឹងកាន់តែច្បាស់ពីលក្ខណៈនៃព្រះជាម្ចាស់ដែលជាអ្នកបង្កើត។ ទ្រង់បានមានបន្ទូលឲ្យព្យាការីមូហាំម៉ាត់(សូមសន្តិភាព និងពរជ័យកើតមានដល់លោក) ប្រកាសប្រាប់យ៉ាងច្បាស់អំពីលក្ខណសម្បត្តិរបស់ទ្រង់ថា៖

១- « ចូរពោលថា៖ អល់ឡោះ គឺជាព្រះជាម្ចាស់តែមួយព្រះអង្គគត់។
២- អល់ឡោះ គឺជាម្ចាស់ដែលភាវៈទាំងឡាយត្រូវការពឹងពាក់។
៣- ទ្រង់មិនបានប្រសូតបុត្រ និងក៏មិនត្រូវបានគេប្រសូតទ្រង់មកដែរ។
៤- ហើយគ្មានអ្វីមួយអាចប្រៀបប្រដូចនឹងទ្រង់បានឡើយ។ »
[ព្រះគម្ពីរគួរអាន ១១២ ៖ ១-៤]

អត្ថន័យនៃជំពូកនេះ គឺប្រៀបដូចជាកំពុងឆ្លើយនឹងសំណួរថា៖ «តើអល់ឡោះជានរណា?» ដែលចម្លើយនោះគឺ៖ អល់ឡោះគឺជាម្ចាស់តែមួយព្រះអង្គគត់ ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ និងគ្មានដៃគូនៅក្នុងការគោរពសក្ការៈជាមួយទ្រង់នោះឡើយ។ ទ្រង់គឺជាម្ចាស់ដែលភាវៈទាំងអស់ត្រូវការពឹងពាក់សម្រាប់គ្រប់តម្រូវការរបស់ពួកគេ។ ទ្រង់មហារុងរឿង ថ្កុំថ្កើងលើសពីការមានបុត្រ ឬត្រូវបានគេប្រសូតមក ព្រោះបើមានអ្នកប្រសូតទ្រង់ នោះមានន័យថា គឺនឹងមានអ្នកដែលអស្ចារ្យជាងទ្រង់ទៅទៀត។ ទ្រង់គង់នៅរហូតឥតមានទីផ្ដើម ហើយក៏ឥតមានទីបញ្ចប់ឡើយ។ គ្មានអ្វីអាចប្រដូច ឬស្រដៀងនឹងទ្រង់ ហើយនិងលក្ខណសម្បត្តិរបស់ទ្រង់ឡើយ ដ្បិតទ្រង់គឺជាអ្នកបង្កើតដែលមានលក្ខណៈខ្ពង់ខ្ពស់ហួសប្រមាណ ដែលបញ្ញាមនុស្សមិនអាចនឹងវិនិច្ឆ័យដល់។

នេះជាជំពូកដែលបង្ហាញឱ្យយើងដឹងកាន់តែច្បាស់ពីភាពខុសគ្នារវាងលក្ខណសម្បត្តិនៃព្រះជាម្ចាស់ដែលជាអ្នកបង្កើត និងភាវៈដែលទ្រង់បង្កើត ដោយអល់ឡោះតែមួយព្រះអង្គគត់ជាអ្នកបង្កើត ហើយអ្វីផ្សេងពីទ្រង់ គឺសុទ្ធតែជាភាវៈ ឬជាអ្វីដែលទ្រង់បង្កើតប៉ុណ្ណោះ។

## ហេតុអ្វីបានជាយើងមិនអាចមើលឃើញទ្រង់?

ពិតប្រាកដណាស់ មានរឿងជាច្រើនដែលយើងមិនអាចមើលឃើញ ដូចជាខ្យល់ និងមិនអាចទ្រាំទ្រក្នុងការសម្លឹងមើលចំទៅកាន់វាបាន ដូចជា ពន្លឺព្រះអាទិត្យនៅពេលថ្ងៃជាដើម ប៉ុន្តែយើងជឿអំពីវត្តមានរបស់វា។ ដូចគ្នាដែរ យើងមានជំនឿអំពី

វត្តមានរបស់អល់ឡោះជាម្ចាស់ តាមរយៈភស្តុតាងជាច្រើនដែលទ្រង់បានបង្កើត ទោះបីជាយើងមិនអាចមើលឃើញទ្រង់ក៏ដោយ ព្រោះតែញាណនិងកម្លាំងរបស់យើងមិនអាចទ្រាំទ្រនឹងការឃើញទ្រង់នៅក្នុងលោកិយនេះឡើយ។



« គ្មានអ្នកណាម្នាក់មើលឃើញទ្រង់(នៅក្នុងលោកិយ)ឡើយ ប៉ុន្តែទ្រង់ទេដែលជាអ្នកទតឃើញ(រាល់អ្វីៗទាំងអស់)នោះ ហើយទ្រង់ជាព្រះដ៏ល្អិតល្អន់ជាទីបំផុត ជាព្រះដ៏ជ្រាបដឹងជាទីបំផុត។ » [ព្រះគម្ពីរគួរអាន ៤២ ៖ ១១]

មានព្យាការីម្នាក់របស់អល់ឡោះបានទូលសុំចង់ឃើញទ្រង់ នោះគឺព្យាការីមូសេនៅពេលដែលទ្រង់បានមានបន្ទូលទៅកាន់លោកនៅភ្នំស៊ីណៃ។



« ព្យាការីមូសេបានមានប្រសាសន៍ថា៖ បពិត្រព្រះជាអម្ចាស់ទូលព្រះបង្គំ! សូមទ្រង់មេត្តាបង្ហាញព្រះកាយមកកាន់ទូលព្រះបង្គំ ដើម្បីឲ្យទូលព្រះបង្គំអាចមើលឃើញទ្រង់ផង។ អល់ឡោះបានមានបន្ទូលទៅលោកថា៖ អ្នកនឹងមិនឃើញយើងនោះឡើយ ប៉ុន្តែចូរអ្នកក្រឡេកមើលទៅភ្នំនោះ(ភ្នំស៊ីណៃ)។ ប្រសិនបើវានៅនឹងថ្កល់មួយកន្លែង នោះអ្នកប្រាកដជានឹងឃើញយើង។ ហើយនៅពេលដែលព្រះជាម្ចាស់របស់លោកបានបង្ហាញខ្លួនទៅកាន់ភ្នំនោះ ទ្រង់បានធ្វើឲ្យវាក្លាយទៅជាធូលីដី ហើយមូសេក៏បានដួលសន្លប់នៅលើដី។ នៅពេលដែលលោកភ្ញាក់ឡើង លោកក៏បានមានប្រសាសន៍ថា៖ សិរីរុងរឿងចំពោះព្រះអង្គ! ទូលព្រះបង្គំសូមសារភាពកំហុសចំពោះទ្រង់ ហើយទូលព្រះបង្គំគឺជាអ្នកដែលមានជំនឿដំបូងគេ។ »

[ព្រះគម្ពីរគួរអាន ៧ ៖ ១៤៣]

ភ្នំដ៏ធំមហិមាបានបាក់បែក និងញាប់ញ័រចំពោះការបង្ហាញព្រះកាយរបស់អល់ឡោះទៅកាន់វា។ ដូច្នេះ តើមនុស្សដែលមានកម្លាំងទន់ខ្សោយអាចនឹងទ្រាំទ្របានដោយរបៀបណា?

## គោលគ្រឹះនៃសាសនាអ៊ីស្លាម

សាសនាអ៊ីស្លាមមានគោលគ្រឹះចំនួនប្រាំ៖

ទី១៖ ការសច្ចាថា « គ្មានទេព្រះដែលស័ក្តិសមនឹងគោរពសក្ការៈ លើកលែងតែអល់ឡោះ ហើយមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់ទ្រង់ »។

ទី២៖ ការប្រតិបត្តិថ្វាយបង្គំប្រាំដងក្នុងមួយថ្ងៃ។

ទី៣៖ ការដកទ្រព្យមួយចំណែកតូចចំពោះអ្នកដែលមានទ្រព្យដល់ចំនួនដែលបានកំណត់ម្តងក្នុងមួយឆ្នាំ ដើម្បីផ្តល់ឲ្យអ្នកក្រីក្រ និងអ្នកមានតម្រូវការ។

ទី៤៖ ការបួសតមអាហារខែរ៉ម៉ាឌនក្នុងមួយឆ្នាំម្តង។

ទី៥៖ ការធ្វើធម្មយាត្រាហាជ្ជី ដោយត្រូវធ្វើនៅទីក្រុងមេកា(ម៉ាក្កះ) ប្រទេសអារ៉ាប៊ីសាអ៊ូឌីត ឱ្យបានម្តងក្នុងមួយជីវិតសម្រាប់អ្នកដែលមានលទ្ធភាព និងសមត្ថភាព។

## គោលគ្រឹះនៃជំនឿ

សាសនាអ៊ីស្លាមមានគោលគ្រឹះនៃជំនឿចំនួនប្រាំមួយ៖

ទី១៖ ការមានជំនឿចំពោះអល់ឡោះជាម្ចាស់ ដោយទ្រង់តែមួយព្រះអង្គគត់ គឺជាអ្នកបង្កើត គ្រប់គ្រង ផ្តល់លាភសក្ការៈ ផ្តល់ជីវិតរស់នៅ និងសេចក្តីស្លាប់។ ទ្រង់តែមួយព្រះអង្គគត់ដែលស័ក្តិសមនឹងគោរពសក្ការៈ។

ទី២៖ ការមានជំនឿចំពោះទេវតាទាំងឡាយដែលអល់ឡោះជាម្ចាស់បានបង្កើតមកពីពន្លឺ ដើម្បីឱ្យពួកគេគោរពសក្ការៈទៅចំពោះទ្រង់ និងអនុវត្តតាមយ៉ាងពេញលេញចំពោះបទបញ្ជាទាំងឡាយរបស់ទ្រង់។ ហើយនៅក្នុងចំណោមពួកគេ គឺមានទេវតាជីព្រីលជាអ្នកនាំសារពីអល់ឡោះមកកាន់បណ្តាព្យាការី។

ទី៣៖ ការមានជំនឿចំពោះព្រះគម្ពីរទាំងឡាយ ដែលអល់ឡោះបានបញ្ចុះមកកាន់បណ្តាព្យាការី។ ហើយព្រះគម្ពីរគួរអាន គឺជាគម្ពីរចុងក្រោយដែលត្រូវបានបញ្ចុះទៅកាន់ព្យាការីមូហាំម៉ាត់ និងត្រូវបានទ្រង់ថែរក្សាមិនឱ្យមានការកែប្រែនោះឡើយ រហូតដល់ថ្ងៃបរលោក។

ទី៤៖ ការមានជំនឿចំពោះអ្នកនាំសារទាំងឡាយ ដោយព្រះជាម្ចាស់បានចាត់ពួកគាត់មកកាន់មនុស្សជាតិ និងបានបញ្ជូនគម្ពីរមកជាមួយពួកគាត់ ដើម្បីណែនាំ និងដាស់តឿនដល់ពួកគេ។

ទី៥៖ ការមានជំនឿចំពោះថ្ងៃបរលោក ដោយនៅថ្ងៃនោះ ព្រះជាម្ចាស់នឹងឱ្យមនុស្សរស់ពីផ្នូរឡើងវិញដើម្បីជំនុំជម្រះចំពោះទង្វើរបស់ពួកគេ។ អ្នកដែលមានជំនឿ ហើយនិងប្រព្រឹត្តអំពើល្អនោះ នឹងទទួលបានទូវសេចក្ដីសុខជាអមតៈនៅក្នុងឋានសួគ៌។ ចំណែកឯអ្នកដែលគ្មានជំនឿ និងប្រព្រឹត្តអំពើអាក្រក់វិញនោះនឹងទទួលទណ្ឌកម្មដ៏ធ្ងន់ធ្ងរនៅក្នុងភ្លើងនរក។

ទី៦៖ ការមានជំនឿចំពោះព្រះលិខិត ដោយទ្រង់បានកំណត់ និងកត់ត្រានូវរាល់អ្វីៗទាំងអស់ដែលកើតមានឡើងទាំងអស់នោះរួចជាស្រេចនៅក្នុងក្រាំងកំណត់ត្រារបស់ទ្រង់មុននឹងទ្រង់បង្កើតវា។ ហើយរាល់អ្វីដែលទ្រង់មានចេតនាចង់ឱ្យមាន ទ្រង់នឹងបង្កើតវាឡើង ដោយគ្មានការភាន់ច្រឡំ ឬកំហុសឆ្គងនោះឡើយ។

## ជីវិតពិតជាត្រូវការសេចក្ដីណែនាំ

ដើម្បីប្រើប្រាស់អ្វីមួយឱ្យបានល្អត្រឹមត្រូវ គឺយើងត្រូវមើលនូវសេចក្ដីណែនាំរបស់វាជាមុន។ ដូចគ្នាដែរ ដើម្បីប្រើប្រាស់ជីវិតរស់នៅរបស់យើងឱ្យបានល្អត្រឹមត្រូវ គឺយើងត្រូវការសេចក្ដីណែនាំពីអ្នកដែលបង្កើតយើងមក។ ទ្រង់មិនបានបង្កើតយើងមកឱ្យប្រើប្រាស់ជីវិតដោយគ្មានការណែនាំនោះឡើយ។

អល់ឡោះទ្រង់បានចាត់អ្នកនាំសារ ហើយបានបញ្ជូនគម្ពីរមកជាមួយពួកគាត់ ដើម្បីណែនាំ និងបង្ហាញដល់មនុស្សគ្រប់គ្នានូវមាគ៌ាដែលត្រឹមត្រូវ វែកញែករវាងសេចក្ដីពិត និងសេចក្ដីមិនពិត និងអំពាវនាវឱ្យស្គាល់អល់ឡោះ និងគោរពសក្ការៈចំពោះទ្រង់តែមួយព្រះអង្គគត់។



« ហើយយើងមិនបានបញ្ជូនអ្នកនាំសារណាមួយមុនអ្នកឡើយ លើកលែងតែយើងបានបើកបង្ហាញដល់គេថា គ្មានព្រះឯណាផ្សេងក្រៅពីយើងឡើយ។ ដូច្នេះ ចូរគោរពសក្ការៈមកចំពោះយើង។ »
[ព្រះគម្ពីរគួរអាន ២១ ៖ ២៥]

អ្នកនាំសារ គឺជាអ្នកដែលប្រាប់យើងអំពីព្រះជាម្ចាស់ពិតប្រាកដ និងព្រះបរមលក្ខណៈរបស់ទ្រង់។ តាមរយៈពួកគាត់ គឺយើងបានស្គាល់ទ្រង់ ដឹងពីរបៀបនៃការគោរពសក្ការៈចំពោះទ្រង់ និងដឹងពីវិធីដែលធ្វើឱ្យរួចផុតពីទណ្ឌកម្មនៅថ្ងៃបរលោក ដែលជាថ្ងៃដែលទ្រព្យសម្បត្តិ និងកូនចៅមិនអាចផ្តល់ផលប្រយោជន៍អ្វីនោះឡើយ លើកលែងតែអ្នកដែលត្រឡប់មកជួបនឹងអល់ឡោះដោយដួងចិត្តបរិសុទ្ធប៉ុណ្ណោះ។

ដួងចិត្តបរិសុទ្ធ គឺជាដួងចិត្តដែលមានជំនឿថា អល់ឡោះ គឺជាព្រះពិតប្រាកដ ហើយថ្ងៃបរលោកនឹងមកដល់ដោយគ្មានការសង្ស័យឡើយ។

ដំណឹងរបស់ព្យាការី និងអ្នកនាំសារទាំងឡាយអំពីអល់ឡោះ រួមជាមួយនឹងការប្រទានទូវការណ៍អស្ចារ្យជាច្រើនដល់ពួកគាត់នេះ គឺដើម្បីផ្តល់ដំណឹងល្អ និងជាការដាស់តឿនព្រមានដល់មនុស្សគ្រប់គ្នា។ លើសពីនេះ ទ្រង់បានផ្តល់ឲ្យមនុស្សនូវសភាវគតិដែលអាចឱ្យគេបានស្គាល់ទ្រង់តាមរយៈវា និងផ្តល់ឲ្យគេនូវប្រាជ្ញាញាណដើម្បីសញ្ជឹងគិតអំពីការបង្កើតរបស់ទ្រង់។ ហេតុនេះ គឺគ្មាននរណាម្នាក់មានលេសតវ៉ានឹងអល់ឡោះនៅថ្ងៃជំនុំជម្រះឡើយ។

ជាការពិតណាស់ អល់ឡោះជាម្ចាស់បានបញ្ជូនអ្នកនាំសារជាច្រើនមកកាន់មនុស្ស ហើយអ្នកនាំសារចុងក្រោយ គឺមានឈ្មោះថា មូហាំម៉ាត់ (សូមសុខសន្តិភាពកើតមានដល់លោក)។ ទ្រង់បានចាត់លោកមកជាមួយនឹងក្រឹត្យវិន័យចុងក្រោយ ដោយបានប្រទានដល់លោកជាមួយនឹងការណ៍អស្ចារ្យបំផុត គឺគម្ពីរគួរអានដ៏បរិសុទ្ធ ដែលជាព្រះបន្ទូលរបស់ទ្រង់។ គឺជាគម្ពីរដ៏អស្ចារ្យបំផុតដែលមនុស្សជាតិធ្លាប់ស្គាល់ ទាំងខ្លឹមសារ ពាក្យពេចន៍ និងរចនាបថនានា។ ជាគម្ពីរដែលណែនាំទៅកាន់សេចក្តីពិត និងនាំទៅរកសុភមង្គលក្នុងជីវិតលោកិយ និងជីវិតបន្ទាប់(បរលោក)។ គម្ពីរមួយនេះត្រូវបានថែរក្សារហូតមកដល់សព្វថ្ងៃនេះជាភាសាអារ៉ាប់ ដែលជាភាសាដើមដែលត្រូវបានបញ្ជូនចុះមក ដោយគ្មានការផ្លាស់ប្តូរ ឬការកែប្រែឡើយ សូម្បីតែមួយតួអក្សរ។៚

*ស្វែងយល់បន្ថែម*

Google

the fastest growing religion in the world

All | Images | Videos | News | Short videos | Forums | Web | More | Tools

AI Overview

Islam is generally considered the fastest-growing religion in the world. According to a study by Pew Research Center, this growth is primarily attributed to a relatively young population and high fertility rates within the Muslim community. By the end of the century, Muslims are projected to outnumber Christians according to Wikipedia.

Growth of religion - Wikipedia
By the end of 2100 Muslims are expected to outnumber Christians. According to the same...
Wikipedia, the free encyclopedia



Major religious groups - Wikipedia
The 2020 global percentage of adherents by religion. * Christianity (28.8%) * Islam (25.6%) ...
Wikipedia



Pew Research Center

Search pewresearch.org...

RESEARCH TOPICS | PUBLICATIONS | OUR METHODS | SHORT READS | TOOLS & DATASETS | EXPERTS | ABOUT US

Home › Research Topics › Religion › Religious Demographics › Pew-Templeton Global Religious Futures Project

REPORT | APRIL 2, 2015 SHARE

# The Future of World Religions: Population Growth Projections, 2010-2050

*Why Muslims Are Rising Fastest and the Unaffiliated Are Shrinking as a Share of the World's Population*



*Note (June 2025): Religious composition estimates in this report are based on 2010 baseline numbers that have since been updated. Please refer to our 2025 report "How the Global Religious Landscape Changed from 2010 to 2020" for the latest 2010 and 2020 religious composition estimates. New projections past 2020 are not yet available. Refer to the 2025 report, methodology and interactive table for more detail.*

REPORT MATERIALS

- Complete Report
- Data Sources by Country
- Defining Religious Groups
- Religious Composition by Country, 2010-2050

TABLE OF CONTENTS

**The Future of World Religions: Population Growth Projections, 2010-2050**
Regional and Country-Level Projections
About These Projections
Acknowledgements
Roadmap to the Report
Chapter 1: Main Factors Driving Population Growth
Chapter 2: Population Projections by Religious Group
Christians
Muslims
Religiously Unaffiliated
Hindus
Buddhists

អ៊ីស្លាមជាសាសនាដែលរីកសុសសាយលឿនបំផុតនៅលើពិភពលោក


គាស់សំណួរក្នុងខ្លួន
ដើម្បីស្វែងរកចម្លើយពិត